UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**

**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

# សេចក្តីថ្លែងការណ៍ជាសាធារណៈ

ភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨

## *បណ្តឹងសាទុក្ខរបស់សុខ សំអឿន និងប៊ិន សំណាង នៅមុខតុលាការកំពូលកម្ពុជា ចំពោះការផ្តន្ទាទោសពីបទឃាតកម្មគិតទុកជាមុនលើលោកជា វិជ្ជា អ្នកដឹកនាំសហជីព*

ឃាតកម្មលើមេដឹកនាំសហជីពគឺលោកជា វិជ្ជា នៅកណ្តាលទីក្រុងភ្នំពេញ ក្រោមពន្លឺថ្ងៃច្បាស់ កាលពីថ្ងៃទី២២មករា២០០៤ បានធ្វើឲ្យកម្ពុជាបាត់បង់អ្នកដឹកនាំសហជីពដ៏ក្លាហាន និងមានឥទ្ធិពលម្នាក់ ដែលជាជើងឯកសិទ្ធិការងារ និងសេរីភាពសមាគម។ ឃាតកម្មនេះក៏បានទៅជាឆ្នួននៃវាទប្បដិវាទដែលបន្តរហូតមកទល់ថ្ងៃនេះ ធ្វើឲ្យអន្តរាយដល់នីតិរដ្ឋនៅកម្ពុជា ពង្រឹងវប្បធម៌និទណ្ឌភាពនិងធ្វើឲ្យកាន់តែអន់ថយថែមទៀតដល់ជំនឿចិត្តសាធារណៈចំពោះប្រព័ន្ធយុត្តិធម៌មួយដែលកំពុងតែទន់ខ្សោយរួចទៅហើយនោះ។

មានមូលហេតុជាច្រើនដាក់ការសង្ស័យលើសុពលភាពនៃការផ្តន្ទាទោសប៊ិន សំណាង និងសុខ សំអឿន ចំពោះឃាតកម្មនេះ។ ចៅក្រមស៊ើបសួរដំបូង បានលើកលែងចោទ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់។ ចៅក្រមរូបនេះត្រូវបានផ្លាស់ចេញពីតុលាការក្រុង និងលែងឲ្យកាន់សំណុំរឿងនេះទៀត។ រឿងក្តីនេះ ត្រូវបានជំនុំជំរះម្តងទៀតដល់អង្គសេចក្តី ហើយអ្នកទាំងពីរនេះត្រូវបានផ្តន្ទាទោស ដោយឈរលើមូលដ្ឋានចំលើយសារភាពដែលពួកគេបានបដិសេធរួចទៅហើយនោះ ដោយមិនពិចារណាដល់ភស្តុតាង និងសាក្សីដោះបន្ទុក ដែលអះអាងថា អ្នកទាំងពីរមិនអាចទទួលខុសត្រូវចំពោះឃាតកម្មនេះទេ។ ជាជាងពិនិត្យទៅលើចំណុចខ្វះខាតទាំងនេះ សាលាឧទ្ធរណ៍បានតំកល់ការផ្តន្ទាទោសនេះ និងគូសបញ្ជាក់ពីការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន២០ឆ្នាំ។

នៅថ្ងៃទី៣១ ធ្នូ ២០០៨ ខាងមុខនេះ តុលាការកំពូល នឹងបើកសវនាការលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាំងពីរ ចំពោះទោសទណ្ឌរបស់ពួកគេ។

លោកស្រីឧត្តមស្នងការសិទ្ធិមនុស្ស តាមរយៈការិយាល័យប្រចាំប្រទេសកម្ពុជារបស់លោកស្រី បានតាមដានរឿងក្ដីនេះយ៉ាងយកចិត្តទុកដាក់ដោយក្ដីបារម្ភ។ កាលពីខែមិថុនា ២០០៨ លោកស្រីបានដាក់ជូនតុលាការកំពូលនូវសារណាប្រឹក្សាយោបល់មួយក្នុងនាមជាមិត្តរបស់តុលាការ គឺជាសារណាមួយដែលធ្វើការវិភាគទៅលើផ្លូវច្បាប់ ដោយធ្វើចំណាប់អារម្មណ៍លើការបំពានធ្ងន់ធ្ងរជាច្រើនលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយតុលាការថ្នាក់ក្រោម។ កាលពីខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចាប់តាំងពីត្រូវបានធានាការពារដោយមាត្រា៣១ នៃរដ្ឋធម្មនុញ្ញមក គឺជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា។ ដូច្នេះ តុលាការកំពូល ក៏ដូចជាតុលាការកម្ពុជាទាំងអស់ដែរ មានកាតព្វកិច្ចត្រូវធានាថា បទបញ្ញត្តិនានាស្ដីពីសវនាការប្រកបដោយភាពយុត្តិធម៌ មានចែងនៅក្នុងសន្ធិសញ្ញានានាត្រូវតែគោរពតាម ហើយការបំពានទាំងឡាយដោយតុលាការថ្នាក់ក្រោម ត្រូវតែមានដំណោះស្រាយកែសំរួល។

តុលាការកំពូលមិនអាចលើកលែងការផ្ដន្ទាទោសនេះដោយខ្លួនឯងក៏ពិតមែន តែអាចសំរេចបង្វិលរឿងក្ដីនេះឲ្យសាលាឧទ្ធរណ៍ធ្វើការជំនុំជំរះម្ដងទៀត ដោយធ្វើការណែនាំឲ្យបានច្បាស់ពីការគោរពឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ព្រហ្មទណ្ឌកម្ពុជានិងបទដ្ឋានសវនាការប្រកបដោយភាពយុត្តិធម៌អន្តរជាតិ។ ធ្វើដូច្នេះបាន នឹងបង្ហាញពីការប្ដេជ្ញាចិត្តរបស់យុត្តាធិការខ្ពស់បំផុតនៃប្រព័ន្ធយុត្តិធម៌ចំពោះនីតិរដ្ឋមួយដ៏ត្រឹមត្រូវ ហើយបង្កើតជាឧទាហរណ៍វិជ្ជមានដ៏ល្អមួយចំពោះប្រព័ន្ធយុត្តិធម៌ទាំងមូល ព្រមទាំងជាសញ្ញាចាប់ផ្ដើមមួយនៃការខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព។

អ្នកដឹកនាំសហជីពពីររូបទៀត គឺលោករស់ សុវណ្ណារ៉េត និងលោកហ៊ី វុទ្ធី ក៏ត្រូវបានធ្វើឃាតដែរ តាំងពីឃាតកម្មលើលោកជា វិជ្ជាម៉េ្ល៉ះ។ ឃាតកម្មទាំងនេះសុទ្ធតែមានឥទ្ធិពលមិនល្អដល់សេរីភាពសមាគមនៅកម្ពុជា។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គាំទ្រការអំពាវនាវថ្មីៗនេះដោយគណៈកម្មាធិការនៃអង្គការពលកម្មអន្តរជាតិស្ដីពីសេរីភាពសមាគមឲ្យមានការស៊ើបអង្កេតឯករាជ្យ ទៅលើឃាតកម្មអ្នកដឹកនាំសហជីពទាំងបីរូបនេះ និងការមិនបានរកយុត្តិធម៌តាមផ្លូវច្បាប់ដែលទាក់ទងក្នុងរឿងទាំងនេះ។

ចប់